# សម្ភាសន៍ជាមួយឈ្មោះ សួន ស៊ុន ភេទប្រុស អាយុ៥១ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ អតីតទាហានលន់ នល់

មុខងារបច្ចុប្បន្នៈ ទាហានប្រចាំការនៅវរៈ៥០៦

ស្រុកកំណើតនៅភូមិវត្តកំផែង ឃុំស្វាយប៉ោរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង

ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៤៣:៣០

២១ទំព័រ

វណ្ណៈ : ចឹងជាដំបូងខ្ញុំចង់ណែនាំថា ខ្ញុំឈ្មោះ សុខ វណ្ណៈ ហើយខ្ញុំមកនេះគឺចង់ចងក្រងឯកសារទុកជាប្រវត្តិសាស្រ្ត ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង បានពីរឿងរ៉ាវដែលកើតមាន ។ ចឹងពូអនុញ្ញាតិឲ្យខ្ញុំយកទៅសរសេរទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពុដែរ?

ស៊ុន : អនុញ្ញាត ។

វណ្ណៈ : ចឹងខ្ញុំអរគុណពូ ពូឈ្មោះអី?

ស៊ុន : ខ្ញុំ សួន ស៊ុន ។

វណ្ណៈ : សួន ស៊ុន?

ស៊ុន : បាទៗ ។

វណ្ណៈ : អាយុប៉ុន្មាន?

ស៊ុន : ៥៥ ។

វណ្ណៈ : ប្រពន្ធពូឈ្មោះអីដែរ?

ស៊ុន : ហ៊ី ឡាង ។

វណ្ណៈ : គាត់អាយុប៉ុន្មានដែរ?

ស៊ុន : គាត់ប្អូនខ្ញុំ គាត់៤៩ ។

វណ្ណៈ : សព្វថ្ងៃពូកូនប៉ុន្មាន?

ស៊ុន : កូន៣ ។

វណ្ណៈ : ស្រីប៉ុន្មាន?

ស៊ីន ៖ ស្រី១ ប្រុស២ ។

វណ្ណៈ ៖ ចុះឪពុកពូវិញ?

ស៊ីន ៖ ទេព សួន ។

វណ្ណៈ ៖ ទេព សួន?

ស៊ីន ៖ បាទ! ទេព សួន ។

វណ្ណៈ ៖ ចុះម្ដាយ?

ស៊ីន ៖ ម្ដាយ ឌុម ខាន់ ។

វណ្ណៈ ៖ គាត់ទាំងពីរនៅរស់ដែរ?

ស៊ីន ៖ ស្លាប់សម័យប៉ុល ពត ។

វណ្ណៈ ៖ ស្លាប់ជំនាន់ខ្មែរក្រហម?

ស៊ីន ៖ បាទ!

វណ្ណៈ ៖ ស្លាប់ដោយសារអីគេ?

ស៊ីន ៖ ស្លាប់ដោយសារអត់បាយ ។

វណ្ណៈ ៖ អត់បាយ មិនមែនគេយកទៅវ៉ៃចោល?

ស៊ីន ៖ អត់ទេ ធ្វើស្រែនឹង អត់បាយនឹងសម័យខ្មែរក្រហមប៉ុល ពត ។

វណ្ណៈ ៖ គាត់អតីតទាហានលន់ នល់?

ស៊ីន ៖ បាទ! ទាហានលន់ នល់ ទាហានស្ដេចនឹង អតីតនឹង ។

វណ្ណៈ ៖ ចុះភូមិៗកំណើតពូ?

ស៊ីន ៖ នៅភូមិវត្តកំផែង កាលនឹងគេដាក់ភូមិវត្តកំផែង ឃុំស្វាយប៉ោះ កាលនឹងគេដាក់ចឹងឯង ពីដើមមក ។

វណ្ណៈ ៖ ឃុំស្វាយប៉ោះ?

ស៊ីន ៖ សួរពីបច្ចុប្បន្ន ឃុំនឹងយើងដាក់ពីដើម ។

វណ្ណៈ ៖ បាទ! ដាក់ពីដើម ឃុំស្វាយប៉ោះ ស្រុក?

ស៊ីន ៖ ស្រុកស្វាយប៉ោះដែរ ខេត្តបាត់ដំបង ភូមិវត្តកំផែង ។

វណ្ណៈ ៖ ចុះឥឡូវពូនៅណាដែរ?

ស៊ីន ៖ ខ្ញុំធ្វើទាហាននៅកង៥០៦ ។

វណ្ណៈ : ជាទាហានកង៥០៦?

ស៊ុន : វរៈការពារព្រំដែន៥០៦ ។

វណ្ណៈ : វរៈការពារ?

ស៊ុន : ព្រំដែន៥០៦ ។

វណ្ណៈ : ចឹងពូកាលពីតូច ពូរៀនបានថ្នាក់ណាដែរ?

ស៊ុន : រៀនបានថ្នាក់ទី៩ ។

វណ្ណៈ : រៀនបានថ្នាក់ទី៩ដែរ?

ស៊ុន : បាទ! ទី៩ ។

វណ្ណៈ : ហេតុអីបានពូរៀនបានតិចម៉េច?

ស៊ុន : ពេលនោះសម័យសង្គ្រាម បើពេលនោះសម័យសង្គ្រាមបណ្ដោយ ចូលសង្គ្រាម ។

វណ្ណៈ : ចឹងខ្ញុំចង់ឲ្យពូរៀបរាប់កាលដែលពូឈប់រៀន ហើយពូទៅធ្វើអី ហើយចូលដល់សម័យខ្មែរក្រហម ពូជួបការលំបាកយ៉ាងម៉េចខ្លះ ពីទុក្ខសោករបស់ពូ?

ស៊ុន : ពេលដែលខ្ញុំឈប់រៀន ចូលទៅបម្រើកងទ័ពលន់ នល់ ។

វណ្ណៈ : ពូមិនមែននៅខាងខ្មែរក្រហមទេ លន់ នល់?

ស៊ុន : អត់ទេ លន់ នល់ ។

វណ្ណៈ : លន់ នល់ ហើយឈរជើងនៅខាងណា?

ស៊ុន : នៅត្រើយប៉ៃលិនយើងនឹង ។

វណ្ណៈ : ឈប់រៀន ចូលទាហានលន់ នល់ឆ្នាំណា?

ស៊ុន : ខ្ញុំមើល៧០ ៧១ ៧២ ៧៣ ហ្នឹងហើយចូលឆ្នាំ៧០ ។

វណ្ណៈ : ៧០?

ស៊ុន : បាទ! ដើមឆ្នាំ៧០នឹងឯង ។

វណ្ណៈ : ៧០នឹងឈរជើងនៅណា?

ស៊ុន : នៅម៉ាជួរយើងត្រែងប៉ៃលិននឹងឯង ។

វណ្ណៈ : នៅ?

ស៊ុន : បាទ! នៅត្រែង ប៉ៃលិន ។

វណ្ណៈ : ពូកាលនឹងពូចូលតែម្នាក់ឯង ឬក៏មានបងប្អូនពូបង្កើតចូលដែរ?

ស៊ុន : មានមិត្តភ័ក្តិដែលរៀនជាមួយគ្នានឹង ២-៣នាក់នឹង ។

វណ្ណៈ : ចុះពូនៅខាងថ្មើរជើងទេនេះ?

ស៊ុន : ខ្ញុំនៅខាងថ្មើរជើង ។

វណ្ណៈ : ពូនៅតូចៗដែលកាលនឹង?

ស៊ុន : កាំភ្លើងមិនទាន់ផុតពីដីផង អាចូលអាយុ១៧ឆ្នាំ ។

វណ្ណៈ : កាលចូលអាយុ១៧ឆ្នាំ ។ ចឹងដូចថាពូមានបងប្អូនប៉ុន្មាននាក់កាលនឹង?

ស៊ុន : ខ្ញុំមើល មានបងប្អូនស្លាប់អស់ហើយ នៅសល់តែស្រី១ប្រុស២ទេ ។

វណ្ណៈ : ទាំងអស់ប៉ុន្មាននាក់?

ស៊ុន : ៧នាក់ ។ នៅសល់៣សព្វថ្ងៃ ។

វណ្ណៈ : ចឹងសុំពូរៀបរាប់ថា នៅរហូតពូធ្វើទាហានលន់ នល់នឹង តើការច្បាំងគ្នាជាមួយទាហានខ្មែរនឹងជួបការលំបាកយ៉ាងម៉េចខ្លះ?

ស៊ុន : ជួបការលំបាកបើនិយាយពីខាងកងទ័ពវិញវា មិនដែលបានស្រួល វាតែងតែមានការតស៊ូដូចគាត់(អ្នកសម្ភាសន៍មុន) បានលើកមុនចឹង ។

វណ្ណៈ : មានស្លាប់រស់ទាំងសងខាងដូចគ្នា?

ស៊ុន : បាទ! ទាំងសងខាង លន់ នល់ ក៏ងាប់ច្រើន ងាប់សុទ្ធជីកឡានមាន២-៣ឡាននោះខ្មោចដឹក ។ បាទ! ងាប់ច្រើនដែរ ។

វណ្ណៈ : មិនស្រួលកាលនឹងខាងទាហានលន់ នល់ ស្លាប់ជាងទាហានខ្មែរក្រហមទៀត?

ស៊ុន : បាទ! ស្លាប់ជាងច្រើន ។

វណ្ណៈ : ខាងខ្មែរក្រហមគេនៅលាក់ខ្លួនជាមួយប្រជាជន?

ស៊ុន : បាទៗ ។

វណ្ណៈ : ហើយខាងទាហានលន់ នល់ ដើរចេញ?

ស៊ុន : ដើរចេញ ចុះពីឡានបាញ់គ្នាបណ្តោយ ។

វណ្ណៈ : ដើរចេញជាមុខសញ្ញាមើលឃើញម៉ង?

ស៊ុន : បាទ! ...ខ្ញុំធ្លាប់ទៅវៃនៅសមរភូមិព្រៃទ្រីនេះ សុទ្ធតែធ្លាក់ទឹកធ្លាក់ភក់ហើយ ប៉ៃលិនយើងអីនេះ សាលាលេខ៥ គ្រពាំងចាន់ ព្រៃខ្មែរចេញពីស្រុកឃ្លួនមក ខ្ញុំគេបញ្ជូនទៅរៀនស្រុកឃ្លួនមក នៅឡាំសឹន ចេញមកវៃរហូត ។

វណ្ណៈ : ចឹងកាលពូធ្វើទាហានលន់ នល់ កាលនឹងប្រធានកងពល ប្រធានអីពីណាគេ?

ស៊ុន : កាលនឹងបើខ្ញុំស្តាប់មេខ្ញុំ វាមេច្រើន កាលនឹងជិតដាច់ខ្យល់នោះ អាមាស ចាន់លាភ ហើយនឹងមុំ តេង ។ កាលនឹងគេហៅកុម្មង់ដុងបាត់តាយ៉ុងហើយ កាលនឹងគេអត់ហៅដូចយើង គេហៅកុម្មង់ដុងបាត់តាយ៉ុង ប៉ុនឈ្មោះនឹងហើយ ។

វណ្ណៈ : ឈ្មោះអីគេមិញ?

ស៊ុន : មាស ចាន់លាភ ហើយនឹងមុំ តេង ។

វណ្ណៈ : មាស ចាន់លាភ?

ស៊ុន : មេដូរច្រើនដែរ កាលនឹងផ្លាស់ បើថាខាងទាហាននោះ និយាយរួមនឹងហើយមេ មាស ចាន់លាភ, មុំ តេង ។

វណ្ណៈ : កាលនឹងពូធ្វើទាហាន បានប្រាក់ខែប៉ុន្មានកាលនឹង?

ស៊ុន : ប្រាក់ខែតិចណាស់ ធ្វើមិនបាន២០០-៣០០មិនដឹងទេកាលនឹង ។

វណ្ណៈ : ចឹងគឺប្រយុទ្ធគ្នារហូតដល់បែក៧៥ពូ?

ស៊ុន : បែក៧៥ខ្ញុំនៅលន់ នល់ដដែល ខ្ញុំទម្លាក់អាវុធចុះ បងប្អូនយើងខាងនេះចូលមកដល់ចឹងលន់ នល់ពលទោធ្វើស្រែអីចឹងទៅ ។ ហើយយើងពលទោៗ ប្រាប់គេពលទោត្រង់ចឹងទៅ គេយកមកធ្វើស្រែ ដឹកខ្ញុំចេញពីប៉ៃលិនមក ។ ប៉ុនចេះ ខ្ញុំនិយាយនេះតិចកាលដែលដាក់អាវុធនឹង ពួកខ្ញុំទៅថៃក៏បានដែរ ប៉ុននឹកឃើញស្រណោះម៉ែឪ ខ្ញុំអត់ទៅ ។

វណ្ណៈ : ចុះឪពុកពូក្រែងធ្វើទាហានលន់ នល់?

ស៊ុន : ធ្វើទាហានលន់ នល់ទាំងអស់ ។

វណ្ណៈ : ចុះគាត់?

ស៊ុន : នៅបាត់តាយ៉ុងខុសគ្នា ។

វណ្ណៈ : ប្រហែលជាគាត់ធំហើយ តាមមើលមានសក្តិមានអីពាក់?

ស៊ុន : ប្រហែលគាត់កាលនឹងសក្តិ១ទេ គាត់ខាងបើកឡាន ប្រវត្តិគាត់បើកឡានឲ្យអ្នកអធំចឹងទៅ គាត់ទៅរៀន តាំងពីស្តេច តាំងពីទាហានលន់នល់ នៅបៀត ។ ចឹងក្រោយមកខ្ញុំ ពេលទ័ពវៀលុកចូល យើងមិនដាក់អាវុធ ចឹងមានទាហានខ្លះវាបុកទៅថៃ ទៅអាមេរិចទៅអីនោះ ។ ប៉ុនខ្ញុំទៅមិនកើត នៅស្រណោះម៉ែឪ មកធ្វើស្រែ ។

វណ្ណៈ : ចឹងកាលនឹងគេអត់ទាន់ចាប់ចង ចាប់អី?

សុ៊ន ៈ អត់ទេ គេប្រកាសថាពលទោធ្វើស្រែ ជិះឡានជិះអីមកជាមួយម៉ែឪមកធ្វើស្រែ ។

វណ្ណៈ ៈ ចឹងពូៗមកពីប៉ៃលិនវិញ ទៅជួបម៉ែឪនៅបាត់ដំបង?

សុ៊ន ៈ នៅជាមួយគ្នានឹងម៉ង មកតាមប៉ៃលិន មកជាមួយគ្នា ជិះឡានមកជាមួយម៉ែឪទៅ ។

វណ្ណៈ ៈ មកដល់ឈប់នៅណា?

សុ៊ន ៈ ឈប់នៅនឹង កំពុងគល់រោងចក្រ កំពុងគល់ស្ពានសនេះ បានកងទ័ពគេនឹងបែងចែកឲ្យទៅធ្វើស្រែ ទៅខាងនេះផ្សេង ទៅខាងហប់ កោះក្រឡនេះខ្ញុំ ។

វណ្ណៈ ៈ ៧៥ នឹង?

សុ៊ន ៈ បាទ! ពេលដែលចប់ដាក់អាវុធនឹង ។ ដោយខ្មែរក្រហមចឹងទៅ គេចាប់ផ្ដើមធ្វើស្រែ គេឲ្យចបកាប់ ព្រោះខ្ញុំធ្លាប់ធ្វើទាហាន យើងដឹង ដូចថាភ្ជុំកញ្ចែតំរង់ជួរទេប្រឹបៗ ពេលនោះយោធា គេកាន់ក្តាប់ ។ ចឹងយើងជាប់ជានិន្នាការឈ្លើយសឹកទៅចុះ ហើយពួកខ្ញុំមិនមែនប្រជាពល រដ្ឋកាន់ក្តាប់ទេ គឺកងទ័ពអាវខ្មៅកាន់កាប់ម៉ង ។ ដល់កាន់ចឹងទៅ គេឲ្យយើងដកពិសោធន៍ កាន់ធ្វើស្រែអីចឹងទៅ មើលទៅអត់ចំណេញគេដកពិសោធន៍ រកអង្ករ និងនង្គ័លដូចក្របី យើងឲ្យអូស ។

វណ្ណៈ ៈ យើងមនុស្សនឹង?

សុ៊ន ៈ បាទ! មនុស្សនឹងអូសនង្គ័លនឹងមនុស្ស ។

វណ្ណៈ ៈ ចុះធ្វើភ្ជួរស្រែចឹង យកមនុស្សអូសចឹងម៉េចដែរពូ?

សុ៊ន ៈ យកមនុស្សអូសចឹងយើងខ្លាចគេយកទៅបាញ់ចោលដែរ ។

វណ្ណៈ ៈ យើងចេះតែខំទៅ?

សុ៊ន ៈ បាទ! យើងឈ្មោះទាហានស្រាប់ ហើយអ្នកកាន់ពួកអ្នកអាវខ្មៅនឹងឯង យោធាគេនឹង ។ ហើយគេអ្នកកាន់ផ្ទាល់ ហើយយើងប្រជាពលរដ្ឋ ទាំងគេទាំងខ្ញុំ ទាំងស្រីទាំងប្រុស លាយគ្នាសុទ្ធតែម៉ុំទាហាននឹង អូសនង្គ័លនឹងមនុស្ស ។

វណ្ណៈ ៈ ហើយគេឲ្យហូបចុកម៉េចដែរ?

សុ៊ន ៈ បបរ ។

វណ្ណៈ ៈ បបរ?

សុ៊ន ៈ បាទ! បបរម៉ាកា ។

វណ្ណៈ ៈ ចុះឪពុកពូអីនៅជាមួយពូដែរ ក៏បែកគ្នា?

ស៊ុន : ឪពុកខ្ញុំ គាត់បេះខាងជាងដុំដែក គាត់ដុកកាំបិតឲ្យយោធាទៅ ហើយខ្ញុំកាលនឹង ។

វណ្ណៈ : បាទ! នៅកន្លែងនឹងដែរ?

ស៊ុន : បាទ! នៅសហករណ៍ កាលនឹងគេហៅសហករណ៍ ។

វណ្ណៈ : សហករណ៍ប៉ុន្មាន សហករណ៍អីគេ?

ស៊ុន : ...ប៉ុនហៅសហករណ៍ហប់ ហើយនាយកាន់ខ្ញុំឈ្មោះអាប៉ក់ ហើយនឹងតាខឿនៗ គាត់កាន់ខាងនឹងទាំងអស់ ។

វណ្ណៈ : នៅតំបន់ប៉ុន្មាន កន្លែងពូនៅ?

ស៊ុន : តំបន់៥ តាមខ្ញុំមើល តំបន់កោះ ប្អូនឯងដើរស្រាវជ្រាវអាចដឹងតំបន់ ម្តុំយើងចក ម្តុំអីនឹង គេហៅតំបន់៤មិនដឹង តំបន់៥មិនដឹងទេ ខ្ញុំអត់សូវចាំដែរ ។

វណ្ណៈ : ចឹងពេលពូនៅនឹងរហូតដល់៧៩ម៉ង ឬក៏យ៉ាងម៉េចដែរ មានការផ្លាស់ប្តូរយ៉ាងម៉េច?

ស៊ុន : ពេលដែល កាលដែលខ្ញុំសម័យនឹងនោះ យើងមិនវៀតណាមបុកចូលមក ចឹងកងទ័ពវៀតណាមវាំរំដោះ ។ ប្អូនអើយ និយាយទៅបើមេឃងងឹត ដូនកាលពួថាផ្គរលាន់ ស្មានតែកាំភ្លើង បេះនឹកឃើញអញអើយស្មានណាបានៗរស់ ។

វណ្ណៈ : ដូចថាពេលដែលពូធ្វើចឹង ដូចថាគេប្រើអីចឹង ពូភ័យខ្លាចទេ កាលជំនាន់នឹង?

ស៊ុន : ភ័យ វាសួរគេស្តដែរ ប៉ុនខ្ញុំឆ្លាត ខ្ញុំថាមិត្តប្អូនអើយ មិត្តបងទៅមើលកុនទៅ គេចាប់ខ្ញុំទេ ទាហាននោះគេចាប់ទេ បើយប់ឡើងចឹងទៅគេដើរហៅសម្លាប់ ប៉ុនឈ្លបគេនោះ គេដើរត្រុកៗ ចាំស្តាប់និយាយខុសគឺងាប់ហើយ ។ ហើយដំណាំដាំនឹង តែហ៊ានបេះ តែលួចបេះវាដឹងក៏សម្លាប់ចោលដែរ ។

វណ្ណៈ : បាទ! អាកន្លែងពូនៅគឺ?

ស៊ុន : ហប់ ។

វណ្ណៈ : កន្លែងហប់នឹង យកមនុស្សទៅ ។

ស៊ុន : កោះក្រឡ ។

វណ្ណៈ : កោះក្រឡយកមនុស្សទៅសម្លាប់ច្រើនទេ?

ស៊ុន : សម្លាប់ច្រើនណាស់ អាអ្នកខ្ញុំចាំបានណាស់ ខ្ញុំទាហានលន់ នល់ តែគេដាក់ម៉ាដុបទាហាននឹង ។ ចឹងក្រោយមកអាទាហានដែលទៅរៀននៅថៃ លន់ នល់ ពួថាម៉េចៗគេមកតាម

រទេះភ្លើងមក ចុះមកតាមភ្នំធិបតី មកដល់គេដាក់ពួកខ្ញុំឯង បាន២-៣ថ្ងៃ គេយកទៅបាញ់ចោលទាំងអស់ យកទៅបាញ់ចោលម៉ង ។

វណ្ណៈ : ទាហានមកពីថៃ?

ស៊ុន : បាទ! បានមកពីថៃ ពួកនឹងខ្ញុំសួរទៅ ចុះយើងធ្វើស្រែបានម៉ាឆ្នាំ បានពួកនឹងមក ពួកនឹងទៅរៀនខាងកាប៉ាល់ហោះ អាំងស៊ីញ៉ូ ខាងអ៊ុបប៉េរីទ័រ ខាងបើកយន្តហោះ មកប្រហែល ៧០ នាក់ ។

វណ្ណៈ : ចុះមកពីថៃ ទាហានលន់ នល់?

ស៊ុន : ទាហានលន់ នល់ គេទៅរៀននោះ ដល់ពេលនេះគេសុំមកវិញៗ បញ្ជូនមកៗដល់ហប់នឹងអត់មានសល់មួយទេ ពួកនឹងបាញ់ចោលទាំងអស់ ឲ្យធ្វើអីបាញ់ចោល ។

វណ្ណៈ : ប្រហែលជាម៉ាឆ្នាំ ចឹងប្រហែលឆ្នាំ៧៦នេះ?

ស៊ុន : បាទ! ប្រហែលចូលនឹងឯង ។ ក្រោយមកអត់អីស៊ីពេក ជួនកាលដាច់ វានិយាយភាសាមួយដែរ កុំឲ្យដាច់ ឲ្យស្លូតៗបបរ២ស្លាបព្រាដាក់ម៉ាខ្ទះក៏មាន រាវគខ្លោកដាក់នឹងកា តំរង់ជួរគ្នា ដូចខ្ញុំអ្នកពលកម្ម អត់ជួយអ្នកណាបានទេពេលនោះ អត់ជួយទេ អត់ជួយណាបានទាំងអស់ របបគេវាស់ចែក ។ ហើយកាប់ដីខ្លាំងជាងធ្វើការឯកជនទៀត ខ្លាចងាប់ ។

វណ្ណៈ : ចឹងពូដូចថាពូបានរស់ដោយសារពូខំធ្វើការអី?

ស៊ុន : បាទ! ខំ បើមិនខំ គេថាយើងសតិអារម្មណ៍មិនល្អ នៅសតិអារម្មណ៍ គេថាមិនទាន់ ជ្រះស្រឡះការជិះជាន់អី វានិយាយ ។

វណ្ណៈ : ចឹងកន្លែងពូនៅគ្នាច្រើននឹង ស្លាប់អស់ច្រើន?

ស៊ុន : ស្លាប់អស់ច្រើនណាស់ ។

វណ្ណៈ : នៅសល់តិចតួចទេ?

ស៊ុន : បាទៗ នៅសុទ្ធតែទាហានលន់ នល់ នៅនឹងខ្ញុំនឹង ទាហានលន់ នល់នៅហប់នឹង ច្រើនអ្នកទាហាន គ្មានប្រជាពលរដ្ឋទេ គេដាក់ កាលនឹងគេហៅឈ្លើយសឹកដែរពួកខ្ញុំ ។ ដល់ពេលឡើងទៅយកអង្ករយកអី សាក់កាដូដាក់ស្ពាយទៅ ដូចផែនការស្រូវឲ្យបានប៉ុន្មានខែ ប៉ុន្មានឆ្នាំឲ្យបានអី គឺប្រឹងធ្វើណាស់ ឲ្យបានរស់ បើមិនគេបាញ់ចោលហើយ ចឹងយើងប្រឹងធ្វើ ។ ទោះងើយហត់ ទោះលំបាកម៉េចក៏ដោយ គឺប្រឹង ។ ដល់ដាច់ពេលមែនទែន លីញ៉ែតកន្ទក់ ស៊ីទេ ។

វណ្ណៈ : ចុះបងប្អូនពូប៉ុន្មាននាក់ទៀត ស្លាប់នៅក្នុងសម័យនឹង?

ស៊ុន : សម័យនឹងម៉ង ស្លាប់អត់បណ្តោយ ។

វណ្ណៈ : អត់បាយ?

ស៊ុន : បាទ! វាជួនកាលខ្ញុំ ពេលនឹងគ្មានអ្នកណាជួយអ្នកណាបានទេ ប្អូន គ្មានអ្នកណាអាចជួយអ្នកណាបានទេ ។

វណ្ណៈ : ឪពុកម្តាយក៏មិនអាចជួយយើង?

ស៊ុន : អត់បាន ។

វណ្ណៈ : យើងក៏មិនអាចជួយឪពុកម្តាយ?

ស៊ុន : បាទ! អត់បានវាកំណត់ជាគោលរបប ហើយណាមួយយើងទាហានលន់ នល់ស្រាប់ផង យើងមិនហ៊ាន ។

វណ្ណៈ : មិនហ៊ានទេ?

ស៊ុន : ប៉ុន្អ្នកខ្លះមានលួចៗរត់បាន ។

វណ្ណៈ : រត់ទៅណាវិញ?

ស៊ុន : រត់ទៅតាមកុហក់គេ សំបុត្រក្លែងក្លាយចេះទៅៗណាទៅណែខ្លះរួចបាន មិនដឹងទៅណារួចបានចុះរួចបាន បាត់ខ្លះៗតឹងយើងអាក្រោយនេះបណ្តោយ ។ បាននិយាយថាខំមិត្តយើង ប្រយ័ត្ន ។

វណ្ណៈ : អូ! ដំបូងៗឲ្យតែស្គាល់មេ យើងចេះសញ្ញេបន្ទំអីចឹង?

ស៊ុន : វាឆ្លតវា វាមិនសូវចេះអក្សរ វាមើលទៅឃើញចេះទៅអូទៅ អាខ្លះវាចេះវាឆ្លាត វាប្រចុយឯវាប់នោះ សំបុត្រក្លែងក្លាយ ហើយអាពួកអានឹងវាចេះអីវា ។

វណ្ណៈ : តែដឹងឯវាប់ហើយ?

ស៊ុន : បើសិនអាចខ្លះវាមើលបញ្ច្រាស វាមិនដឹងវាអី!វាឃើញសំបុត្រ បើយើងអ្នកមិនរៀនៗទេ អត់រៀនទេ ។

វណ្ណៈ : ចុះបើគិតថានៅក៏ឯវាប់ដែរ ប្រចុយម៉ងទៅ?

ស៊ុន : អានឹងគិតផ្សេងពីគ្នា យើងថាអញមិនទៅទេ បើមានម៉ែឪគាត់មិនទាន់ស្លាប់មិនទាន់នេះដល់ពេលគាត់ស្លាប់ចឹងបានថាប្រចុយទៅ ។

វណ្ណៈ : ពេលមានសំបុត្រទៅ២-៣នាក់?

ស៊ុន ៖ ទៅផ្សេងៗ ទៅឃើញសំបុត្រឲ្យបាយស៊ី វាទទួល ។

វណ្ណៈ ៖ វាស្មានអ្នកធំមកពីលើ?

ស៊ុន ៖ បាទ! វាដូចចឹងអានឹងវាម៉េចវា ដល់យើងមិនហ៊ានៗទៅ ។

វណ្ណៈ ៖ ចុះពូឆ្លងកាត់នៅក្នុងសម័យពាឆ្នាំនឹង ពូឃើញថារបបនឹងវាយ៉ាងម៉េចដែរពូ?

ស៊ុន ៖ របបនឹង បើខ្ញុំគិតមើលទៅវាសម្លាប់ពេក វាអត់ល្អ បើស៊ីឆ្អែតមានអីត្រឹមត្រូវស្មើភាព វា ល្អ ប៉ុនដល់ពេលវាសម្លាប់ពេក ហើយគ្មាន វាសម្លាប់ពេក ។ ដល់វាសម្លាប់ពេក វាពិបាក មួយអារម្មណ៍អញមិនដឹងងាប់ថ្ងៃណាទេ ព្រោះយើងជាទាហានស្រាប់ៗយើងអារម្មណ៍ជាង ប្រជាពលរដ្ឋ ។ ខ្ញុំម្ដងប្អូន គេហៅទៅកាលនឹងវៀតណាមចូលមកដល់ គេចាប់ផ្ដើមយក លេសអ្នកកាប់ចំការ ។ អ្នកដែលគេយកទៅកាប់ចំការ ដែលគេថានឹងគឺស្លាប់ទាំងអស់ ។ ខ្ញុំនឹងហើយដឹកទៅផ្ទាល់ ខ្ញុំភ័យទៀតខ្ញុំអត់ដឹង ដឹកអ្នកចំការស្មាននឹង ហើយបងខ្ញុំរត់ឡើងភ្នំ ហើយខ្ញុំនៅ ។

វណ្ណៈ ៖ ៧៩ហើយនឹង?

ស៊ុន ៖ នៅពេលវៀតណាមជិតបុកចូលហើយនឹង បន្ទាប់មកគេខ្ញុំមានពួកដឹកទៅកាប់ចំការ ខ្ញុំអត់ដឹងស្រាប់តែទៅដល់ប៉ឹប គេដាក់ក្នុងគុកនឹងគេហៅកន្លែងនឹងបើនិយាយទៅគោកត្រុំនេះឯង ដាក់ទៅស្រែកអួយៗ ខ្ញុំថាដេកអត់លក់ទេ នឹកក្នុងចិត្តតិច ។ នែក! អ្នកកាប់ចំការវាថាឲ្យ អ្នកបរទេះដែរនឹង នឹកក្នុងចិត្តដេកអត់លក់សោះខ្ញុំ ។ ដល់ពីព្រលឹមឡើង អ្នកដែលដឹកមក ទៅអង្គភាពវិញ និយាយពីអរ ដេកព្រមនុស្សថ្ងូរសោះ សុទ្ធតែសេកាបេ ។

វណ្ណៈ ៖ សេអ៊ីអា?

ស៊ុន ៖ សេអ៊ីអា សេកាបេ ប៉ឹបៗវ៉ើ ។ ខ្ញុំនេះញាក់ដេកក្នុងរទេះ បើនៅតែព្រទៅអីថា មើលទៅបានមកនិយាយពីអរណាស់ ខ្ញុំអរណាស់ ។

វណ្ណៈ ៖ ទាំងគេទាំងយើងដឹងធ្វើម៉េចឲ្យតែរស់?

ស៊ុន ៖ បាទ! ចឹងបានខ្ញុំបេះដេកគិតថា អញពីសង្គ្រាមលន់ នល់ មកដល់សម័យនេះបានរស់ ហើយមកដល់សម័យនេះបានចំណាស់នេះ ខ្ញុំមិនដឹងធ្វើបុណ្យប៉ុន្មានវត្តទេ ពីដើមមក មិនដឹងប៉ុន្មានវត្តទេ ។

វណ្ណៈ ៖ ចឹងសុទ្ធតែអ្នកថ្ងៃហើយបានរស់?

ស៊ុន ៖ បាទ!

វណ្ណៈ ៖ ចឹងពូនិយាយតទៀត ចឹងពូគិតថា កាលនឹងពូដឹងថាមានការអត់ឃ្លាន មានការសម្លាប់អីតាំងពីពេលនឹងមក ពូដឹង?

ស៊ុន ៖ បាទ! ខ្ញុំដឹងៗច្បាស់ ព្រោះខ្ញុំនេះដូចខ្ញុំនិយាយប្រាប់ប្អូនឯងចឹង ថាខ្ញុំរស់មកដល់ពេលនេះខ្ញុំមិនដឹងធ្វើបុណ្យប៉ុន្មានវត្តទេ ។

វណ្ណៈ ៖ ពូដឹងថាកាលនឹងដូចថាប្រជាជនលំបាកខ្លាំងនៅឆ្នាំណា?

ស៊ុន ៖ ឆ្នាំដែរ ។

វណ្ណៈ ៖ ជិតបែកហើយ?

ស៊ុន ៖ ហ្នឹងហើយជិតបែក ទី១បានបាយស៊ី ។ ប៉ុនចេះ បាយនឹងបានដោយសារតែយើងពេលបន្តុបង្កើនផលហើយទេ បាយរបស់អង្គការ ព្រោះពួកខ្ញុំអួសអង្ករនិងមនុស្សវាហេវ វាអួសមិនរួចទេ មិនមាត់ទេ ។

វណ្ណៈ ៖ មិនបាច់ហូបទេ បានបាយផ្អែមម៉ង?

ស៊ុន ៖ បាទ! បានបាយអំបិលអីអរណាស់ ។ ហើយបានបាយនឹងមក យើងច្នៃប្រឌិត តែគេឃើញគេចាប់យើងយកទៅវៃចោលដែរ របបប៉ុន្មានគេឲ្យស៊ីប៉ុននឹង បើយើងអត់ច្នៃប្រឌិតតិចទេ អត់ទៅរួចទេ ។ ប៉ុន្តែខ្ញុំឃើញជាក់ ស្តែង ដូចជាអ៊ីវ៉ាន់យើងដាំតាមផ្ទះ វាឲ្យផ្ទះនៅចឹង តែបេះមកឃើញគឺវៃចោលម៉ង ។

វណ្ណៈ ៖ អត់មានយកទៅអប់រំអីសិន?

ស៊ុន ៖ អត់ទេ កន្លែងខ្ញុំគឺវៃចោល វាចោទថាក្បត់សមូហភាព ក្បត់មិត្តយើង វាចោទទៅចឹងអាដាំខ្លួនឯងសោះនឹង ។

វណ្ណៈ ៖ ចឹងដូចថាកាលពូរស់នៅ គណៈតំបន់ គណៈអីពូបានស្គាល់ គណៈភូមិភាគអី?

ស៊ុន ៖ ខ្ញុំមិនដែរទេ ពុថាអង្គការៗមិនដឹងអង្គការណាទេ ។

វណ្ណៈ ៖ ពុតែពាក្យអង្គការមួយ?

ស៊ុន ៖ បាទ! អង្គការលើៗ ប៉ុស្គាល់ច្បាស់ជាងគេអាប៉ុស្ត័កាន់ក្តាប់ខ្ញុំផ្ទាល់ ចុះវាដើរវាស់ដីឲ្យធ្វើស្រែ ឲ្យកាប់ប្រឡាយ ហើយគ្មានទំនេរប្អូនអើយ ។

វណ្ណៈ ៖ ចឹងរាល់ការដូចថាស្លាប់របស់ប្រជាជន ហើយនឹងការអត់អាហារនឹង ពូជឿថាថ្នាក់ដឹកនាំកំពូលៗនឹង បានដឹងដែរ ឬក៏មិនបានដឹងទេ?

ស៊ុន ៖ ជឿថាប្រហែលជាដឹង ព្រោះអ៊ីៗគេបានផលបានអីវាយការណ៍ឲ្យថ្នាក់លើ ប៉ុនថាមិនឲ្យស៊ី មិនឲ្យស៊ីផ្អែតម៉ង និយាយរួមមិនឲ្យស៊ីផ្អែតម៉ង ឲ្យស្លាប់ប៉ុនយើងមិនស្លាប់ ។

វណ្ណៈ ៖ ចឹងនៅកាលសម័យនឹងអត់មានវត្តមានអាអីទេ ពូគិតថាអ្នកដឹកនាំធ្វើចឹងល្អដែរ ឬក៏មិនល្អទេ?

ស៊ុន ៖ ខ្ញុំនឹកថាអត់ល្អ ព្រោះខ្មែរយើងតែងមានកន្លែង ប៉ុនអត់ធ្លាប់ចាស់ៗខ្លះគាត់មានថ្ងៃសីល ថ្ងៃអីគាត់ស្រក់ទឹកភ្នែក ជួនកាលគាត់មានអីជុតទៅណា គាត់បន់ទៅដូចថាតែមាត់ទៅ ចេះតែថាទៅ មានលោកអី ព្រោះវាយកវិហារធ្វើឃ្លាំងស្រូវ ។

វណ្ណៈ ៖ ចឹងជីវិតមនុស្សរស់ ទម្រាំបានឆ្លងកាត់មួយៗនឹង គឺថ្ងៃមែនទែនហើយ?

ស៊ុន ៖ ថ្ងៃ ប្អូនឯងគិតទៅ ខ្ញុំដូចថាខ្ញុំបែបថ្ងៃដោយសារធ្វើបុណ្យពីជាតិមុនម៉េចៗទេ ។ តែទាហានលន់ នល់ យើងឆ្លងផុតពីសង្គ្រាមបានយើងរស់ ដល់សម័យកាប់សម្លាប់នេះយើងរស់ ដល់សម័យច្បាំងគ្នាទៀត ខ្ញុំធ្វើតាំងពីសេនាជនមកដល់ពេលនេះទៀត ខ្ញុំអត់អី ។ ចឹងបានន័យថាខ្ញុំអត់តូចចិត្តវាសនាខ្លួនខ្ញុំ បានថាដូចមានភ័ព្វវាសនាបានមើលនេះ អាផ្លូវចេះៗដែរបានមើល ។

វណ្ណៈ ៖ ចុះពូដូចថាពេលវៀតណាមចូលដល់បាត់ដំបង ចូលដល់អីចឹង ពេលដែលខ្មែរក្រហមរត់មកជាយដែន កាលនឹងពូរត់ទៅស្រុកកំណើតវិញ ឬក៏ទៅតាមទៅណាណៃដែរ?

ស៊ុន ៖ ពេលនឹង ពួកកងទ័ពខាងអាវខ្មៅនឹង គេបែកផ្លូវគ្នា យើងក៏បែកផ្លូវគ្នា ចេះជម្លៀសទៅត្រជាក់ចិត្ត ខ្ញុំខាងមោង ។

វណ្ណៈ ៖ ត្រជាក់ចិត្តខាងណាវិញ?

ស៊ុន ៖ នៅខាងមោងត្រជាក់ចិត្តទៅ ដល់កងទ័ពខាងនេះបុកខ្លាំងមែនទែនវាប្រែន ខ្ញុំប្រុចមកតាមនេះ បានបណ្ដោយ ។

វណ្ណៈ ៖ ទៅស្រុកភូមិវិញ ។

ស៊ុន ៖ ទៅស្រុកភូមិកំណើត មកដល់មោងនេះ អាណាទៅភ្នំពេញទៅៗ អាណាមកបាត់ដំបងមកៗ អាណានៅណានៅទៅពាសពេញតែនឹងឯង ។ ពេលនឹងពាសវាលហើយរកគោលដៅរៀងខ្លួនហើយ ។ ទៅមកបាត់ដំបងមក គេយកស៊ុំគេនៅអីនៅ ព្រោះផ្ទះយើងនៅប៉ៃលិនៗកាលនឹងយើងមិនទាន់បានចូលណា នៅខ្មែរក្រហមនៅឡើយ ខ្ញុំមិនបានទៅទេ ។

វណ្ណៈ ៖ នៅបាត់ដំបង?

ស៊ុន ៖ បាទ! នៅបាត់ដំបងនេះទៅ ។

វណ្ណៈ ៖ ចុះក្រោយមកទៀត ពូធ្វើអី?

ស៊ុន ៖ ក្រោយមកទៀត ចូលធ្វើសេនាជនភូមិ ក្រោយមកគេថាសេនាជនគេថាច្បាំងដែរ ។ គេដាក់មកធ្វើទាហានៗទល់ឥឡូវនេះ ។

វណ្ណៈ ៖ ទាហានខាងសម្តេចហ៊ុន សែន?

ស៊ុន ៖ បាទ! ទាហានសម្តេចហ៊ុន សែន ទល់ឥឡូវ ។

វណ្ណៈ ៖ ចឹងខ្ញុំចង់ដឹងថា កាលទាហានសម្តេចហ៊ុន សែន ដែលសហការណ៍ជាមួយទាហានវៀតណាម នៅជាមួយទាហានខ្មែរក្រហមនឹង តើការគ្រោះថ្នាក់របៀបម៉េចម៉ាសារនឹងទៀត?

ស៊ុន ៖ ម៉ាសារនឹងគ្រោះថ្នាក់តាមដែលយើងធ្វើសង្គ្រាមយើងវាសងខាងប្អូន សងខាងនេះ រឿងខាងនេះស្លាប់ប៉ុន្មានរបួសប៉ុន្មានខាងនេះៗ យើងថ្នាក់តូចយើងមិនដឹងទេ តែឃើញងាប់ៗហើយ ។

វណ្ណៈ ៖ ចុះពូតស៊ូតាំងពី៧៩មកដែរ?

ស៊ុន ៖ បាទ! តាំងពីចេញពីកងទ័ពយើងរំដោះមកនឹង ខ្ញុំទៅនៅ.........ខ្ញុំមើលរូបភាពនឹងវាញ៉ៅញ៉ៅពេក ពិបាករស់នៅ ខ្ញុំក៏ត្រឡប់មកវិញ ។ ខ្ញុំត្រឡប់មកក៏លក់នំប៉័ងការ៉េម ។

វណ្ណៈ ៖ ចុះឆ្នាំណាដែលពូចូលទាហានសម្តេចហ៊ុន សែន?

ស៊ុន ៖ ខ្ញុំចូលពី៨០ ឌុង៨១ ។

វណ្ណៈ ៖ ៨១?

ស៊ុន ៖ បាទ! ចូលជាសេនាជនៗមកបានខ្ញុំចូលនេះ គេមិនមែនចូលទេ គេអ្នកគោលឯករាជ្យគេផ្កាប់មេមកម៉ង់ របួតទល់សម័យនេះ ។

វណ្ណៈ ៖ កាលនឹងវាចូលហើយនៅ ពូនៅទៅខាងណាវិញ មកខាងភ្នំព្រឹក្សនឹងដែរ ឬអត់ទេ?

ស៊ុន ៖ បាទ! អត់ទេ ខ្ញុំម៉ាជួរយើងបាត់ដំបង យើងនៅតាំងពីទន្លេ ប៉ែកសំឡូត សែនចៅ ទួលអំពិល៩ ដើមអីនឹង ភូមិសាស្រ្តនៅម៉ាជួរនឹងឯង ពេជ្រចង្វារនែក!កំពីងកំពួយយើងនឹង ។

វណ្ណៈ ៖ ដែលនៅឆ្ងាយមកដល់នឹង?

ស៊ុន ៖ ខ្ញុំអត់ទេ ខ្ញុំនៅកងទ័ពខេត្តនៅបោះទេ មិនមែនកងពលៗគេនៅនេះ ។

វណ្ណៈ ៖ កាលនឹងពូមកជាមួយទាហានវៀតណាមដែរ ឬក៏អត់ទេ?

ស៊ុន ៖ ខ្ញុំធ្លាប់ដើរជាមួយទាហានវៀតណាមដែរ ទៅក្រោម មកខាងព្រៃធំខ្ញុំធ្លាប់ដើរជាមួយ កង ទ័ពវៀតណាមយើងមុខ កងទ័ពវៀតណាមក្រោយទៅ ។ តែការស្នាក់នៅវាដាច់ពីគ្នា ។

វណ្ណៈ ៖ កាលនឹងពូឡើងវៃ ចឹងពូក៏បានដឹងថាព្រៃឈើយើងនៅស្រុកខ្មែរនឹងវាច្រើនដែរ?

ស៊ុន ៖ ច្រើន ពេញនឹងឯង បានថាត្រឹមថានេះបេងស្អាត បេងអីនឹងប៉ុន្មានបានយកកើតទេ បានតែអង្គែលនឹងឯង គ្មានបានយកកើតទេ ។

វណ្ណៈ ៖ ដល់ពេលយើងសមាហរណកម្មហើយ យើងត្រូវគ្នាព្រៃឈើចាប់ផ្ដើមអស់បណ្ដើរៗរហូត ដល់ឥឡូវមានដីទូលាយហើយ?

ស៊ុន ៖ ចឹងបានខ្ញុំមកឈរជើង ខ្ញុំចេះសួរប្រជាពលរដ្ឋថា នឹងពីដើមព្រៃមើលមិនឃើញទេ ដល់ យើងឃើញស្រឡះចេះ ព្រៃឈើច្រើនមែនម៉ាដូរនេះ ។

វណ្ណៈ ៖ ប៉ុន្តែសរសើរភ័ពូសំណាងពូដូចថា ខ្មែរក្រហមដឹងថាទាហាន ប៉ុន្តែខ្មែរក្រហមវាអត់យកទៅ វៃចោលក្លាមដែរ គ្រាន់វាធ្វើបាបយើងអីចឹង ។ ប៉ុន្តែឪពុកម្ដាយ បងប្អូនពូត្រូវបានស្លាប់ ខ្លះដែរ នៅក្នុងសម័យនឹង?

ស៊ុន ៖ ស្លាប់អត់បាយ ។

វណ្ណៈ ៖ អត់បាយ ទូទៅ មិនមែនគ្រួសារទាហាន មិនមែនអីទេ?

ស៊ុន ៖ ទូទៅ បើនៅ ។

វណ្ណៈ ៖ ជនស៊ីវិល?

ស៊ុន ៖ ជនស៊ីវិល បើនៅខ្វែងដូរជម្លៀសពីភ្នំពេញ ងាប់ៗប៉ះត្រង់ណានៅក្នុងម៉ុងស៊ីកូនឯងក៏មាន ដែរ មនុស្សយើងនឹង កូនងាប់នឹងយកសាច់មកស៊ី អាខ្វែងដូរនេះ ។

វណ្ណៈ ៖ នឹងហើយបើខ្ញុំជួបមីងនៅពោធិ៍សាត់ គាត់និយាយ គាត់ថាចុងក្រោយហើយ គាត់អត់ ឃ្លានពេកហើយគាត់ថាកូនគាត់ស្លាប់មួយ ហើយនៅដូចថាទើបនឹងស្លាប់ភ្លាមៗចឹង កូនគាត់ តូចនឹង គាត់ឃ្លានពេកដាច់ចិត្តជាម៉ង់ទៅ ជាម៉ាភ្លៅដាក់ក្នុងកំសៀវ គាត់ថា ពេលចប់៧៩ ហើយគាត់ទៅស្រុកវិញ ។ គាត់ថានឹងហើយ គាត់ថាដែលត្រូវហេវអស់ហើយណា ហូប ម៉ា ឆ្អែតដឹងទេមីងគាត់ថា ដឹងថាម៉ាអាទិត្យកម្លាំងមានម៉ាអាទិត្យ ។

ស៊ុន ៖ ស៊ីមែន?

វណ្ណៈ : នឹងហើយ ។ ដល់ពេលហើយ៧៩ ទៅស្រុក គាត់ថាលាហើយស្រុកខ្មែរ គាត់មានមាស ប៉ុនអីនឹង ឥឡូវគាត់ទៅនៅអាមេរិច ។

ស៊ុន : គាត់មានចឹង ខ្ញុំមានបានទៅអាមេរិចអីគេ នៅស្រុកខ្មែរនឹង ។ ប៉ុន្តែឮដូចគាត់និយាយចឹង គឺជាការពិតមែន ព្រោះចំណុចដែលខ្ញុំនៅវាកងដែលទាហានលន់ នល់ គេថាដាក់ហប់ចឹង ប្រជាជននៅភ្នំពេញគេដាក់ខ្លែងជួរ ។ ពួកនឹងងាប់ច្រើនជាងទាហានណាស់ វាចុះវាធ្លាប់ មានធ្លាប់ស៊ីឆ្ងាញ់នោះ ប៉ះត្រង់ណាអត់ស្គាល់ពស់វែក ក៏ទៅចាប់ពស់វែកក៏មានដែរ ថា ពស់ថ្លាន់ ។

វណ្ណៈ : ពួកភ្នំពេញនឹង?

ស៊ុន : បាទ! ពួកភ្នំពេញនឹង ហើយស្រូវខ្លះមិនស្គាល់ផង ។ ពស់ស្រកាចាស់ថាពស់ថ្លាន់ដែរ ងាប់ នឹងពស់ចឹកនឹងក៏មានខ្លះដែរ វាអត់ស្គាល់ ដល់ពេលនឹងកូនងាប់ចឹងទៅ និយាយមែនខ្ញុំជឿ មែនស៊ីនឹងបណ្តោយ ។ តែវាស៊ើបដឹងថាស៊ីកូនឯងយកវើចោលទៀត ។

វណ្ណៈ : ប៉ុនគាត់នឹងជិតចប់ហើយ៧៩ ជិតចូល៧៩ដែរ?

ស៊ុន : បាទ! ច្រើនអានឹងហើយ វាអត់ឃ្លានណាស់ ។

វណ្ណៈ : ប៉ុន្តែនៅឆ្នាំ៧៨ តាមខ្ញុំដឹងកន្លែងខ្លះថាគោលការណ៍ខ្មែរក្រហមបានមានលិខិតមួយឲ្យបន្ធូរ ស្រាលកុំចាប់ប្រជាជនទៀត ហើយឲ្យប្រជាជនហូបឆ្អែត ។ តែលិខិតនឹងគ្រាន់មិនដឹងថា មានមកហើយម៉េចទេ ប៉ុន្តែ មានអ្នកខ្លះមានបទបញ្ជាថាឈប់សម្លាប់ មានមកពីលើ ។

ស៊ុន : ខ្ញុំឆ្ងល់ប៉ុននេះ កាលដែលវៀតណាមវើ ជិតដល់បុកចូលដល់អីណាណៃ ឆ្ងល់និរតីមកចាប់ ពាយ័ព្យ ខ្ញុំថាម៉េវើគ្នាឯងចឹង និរតីមកចាប់ពាយ័ព្យ ប្រជាជនរួចខ្លួនវិញ ខ្ញុំឆ្ងល់ចឹង ។

វណ្ណៈ : ចាប់តារស់ ញ៉ឹម ចាប់តាអី?

ស៊ុន : បាទ! ចាប់ ម៉េចចឹង ថាអានេះក្បត់ អានោះក្បត់ ហើយប្រជាជនអត់អីទៅវិញ ចេះនាំ គ្នារត់លូនៗតាមកងទ័ពខាងយើងដែរខ្មែរក្រហមនោះ ។ ប៉ុនខ្ញុំសំណាងដែរថ្ងៃនោះ បើវា ហៅទៅកប់ស្រូវអីវ៉ាន់អី បាញ់ចោលអស់ ប៉ុនខ្ញុំអត់បានទៅ ងាប់បាត់ លេខយើងវាខ្ពស់ ទៅកប់ស្រូវអីលាក់បាញ់ចោលទាំងអស់គ្មានសល់ទេ ។

វណ្ណៈ : ចុះពូដូចថាចេញពីកងចល័តនៅ៧៩ហើយ ពូចូលធ្វើទ័ពធ្វើអី មកដល់ឥឡូវពូពាក់សក្តិ ប៉ុន្មានបានគួរសមដែរ?

ស៊ុន : ខ្ញុំ បើនិយាយទៅទាហានអត់ខ្សែ យើងនិយាយ ខ្ញុំបានអនុ-គ បានត្រឹមសក្តិ២ ។

វណ្ណៈ : បើតាមពីជំនាន់៨០ ជាងសុទ្ធតែធំហើយ?

ស៊ុន : បាទ! ចឹងសក្តិខ្ញុំឡើងដោយវេទនាដែរទេ ចឹងបានខ្ញុំចេះប្រាប់កូនរៀនថា សក្តិដែរវេទនា គឺល្អ ។ យើងឡើងពីតូចយើងដឹងថាយើងស៊ីអី............(ស្តាប់មិនបាន) ។

វណ្ណៈ : ដឹងស្រណុកមកពីលើសក្តិធំ ប៉ុន្តែអត់ការតស៊ូ?

ស៊ុន : បាទ! តស៊ូចឹងមក យើងដឹងយើងបានគំរាមយើងកុំធ្វើវា ព្រោះយើងធ្លាប់ចឹងដែរ បាន ច្បាប់ទៅផ្ទះអរដូចគ្នា...... ។

វណ្ណៈ : បាទ! ចុះឥឡូវមកដល់សព្វថ្ងៃនេះ ទាហានតាមព្រំដែនយើងមាននៅច្រើនតាមនឹងដែរ ឬ ក៏មិនសូវមាន?

ស៊ុន : មានតើ មានប៉ូលីសព្រំដែន មានទាហានព្រំដែន តាមនេះចាប់ពីនេះទឹកធ្លាក់រហូតដល់ នោះ ។

វណ្ណៈ : តែយើងមានការភ្លើងធូន់ល្មមៗ?

ស៊ុន : ល្មមៗ យើងមិនបាច់ព្រួយទេអានឹង ។

វណ្ណៈ : ល្អៗ ទៅតាម?

ស៊ុន : មិនបាច់ព្រួយទេអានឹង ជារឿងថ្នាក់លើ ប៉ុន្តែខ្ញុំជឿថាម៉ាដូរនេះ ៗខ្ញុំដឹងថាខ្មែរក្រហមពី ដើមមក ខ្ញុំជឿថាកេមានស្មារតីរឹងប៉ឹងណាស់ នេះម៉ាដូរនេះសុទ្ធតែធ្លាប់ ។

វណ្ណៈ : ហើយមានទំនាក់ទំនងជាមួយគ្នារាល់ថ្ងៃនឹង?

ស៊ុន : រហូតជាមួយគ្នា បុណ្យការទៀនអីជាមួយគ្នា ។

វណ្ណៈ : យើងកំពុងចង់ឲ្យមានសន្ត្រាម ។

ស៊ុន : បាទ! ថៃវិញវាទំនាក់ទំនងធម្មតា ដូចការមុននេះចូលមកស៊ីផឹកជាមួយគ្នាខ្ញុំ ប៉ុន្តែយើងមាន អារម្មណ៍មួយរឿងផ្សេង រឿងថៃដន្យគឺយើងគិតថៃដន្យបណ្តោយ អានេះជារឿងទឹកដី រឿងមនោសញ្ចេតនាយើងដាក់ដោយឡែក រឿងទឹកដីយើងគិតពីនេះវិញ ។

វណ្ណៈ : ថ្វីត្បិតថាប្រទេសយើងកំពុងរីកចំរើនម្តងតិចម្តង ចឹងយើងដោយសារយើងសន្ត្រាមវាយូរ ហើយ នៅថៃអីគេក្លាយជាប្រទេសអ្នកមានដោយសារគេអត់សន្ត្រាម១០០ឆ្នាំហើយ ចឹង បានថាបើសិនបរទេសឈ្លានពានយើងមិនដឹងធ្វើម៉េច យើងត្រូវតែតស៊ូទៀត យើងត្រូវ តែធ្វើទៀត យើងក្រទៀត យើងទៅខ្ចីលុយគេមកទៀត

ប៉ុន្តែយើងមិនចង់ឲ្យមានសង្គ្រាម ទេ គឺឥឡូវនឹងបញ្ហារាល់ថ្ងៃ គឺព្រំដែនព្រះវិហារមួយទេ ដែលយើងពិបាក ហើយនឹងនៅ ខាងបន្ទាយអំពិលអីតិចតួច ។ បើខាងនេះខ្ញុំក្តីបានសុខសប្បាយចឹង ខ្ញុំអរដែរ ។

ស៊ុន : អត់អីទេ ប៉ុន្តែយើងមើលយើងធ្លាប់ធ្វើទាហាន យើងដឹងពីរបៀបគេវៃហើយ ពួកអានេះ វាវៃរបៀបអាមេរិចកាំង ។ បើថាទ្រាំអាគ្រាប់ផ្លោងវាបានហើយឈ្នះវាហើយ បើទ្រាំមិន ចាញ់វា ។ អាសត្វនេះវាល្មមៗវាផ្លោង ចឹងបានយើងខំធ្វើលានដ្ឋានជម្រកអីមាំមួន ខ្ញុំដឹង ល្បិចវាវៃ បានហើយស្ងាត់ចាំដាក់ទៅផាប់មិនចេះតិចទេអានេះ យើងកុំរត់ឲ្យសោះពេល វាផ្លោង រត់ផាប់ច្រើន ក្រាញ់ចាំវាឯងមកដាក់សំរុកចូលបណ្តោយ ។ ពួកនេះវាបាញ់ដូច លន់ នល់ ខ្ញុំធ្លាប់ធ្វើទាហានលន់ នល់ ខ្ញុំដឹង ។

វណ្ណៈ : រត់ត្រូវគ្រាប់វាផ្លោងចូល ។

ស៊ុន : ផ្លោង បើវាជិតញខាងផ្លោង កុំរត់ឲ្យសោះ ។

វណ្ណៈ : ប៉ុន្តែទាល់តែយើងមានលានដ្ឋានមាំដែរ ។

ស៊ុន : បាទ! ប្រើងធ្វើ សព្វថ្ងៃនេះប្រើងធ្វើ........(ស្តាប់មិនបាន) លានដ្ឋានចំរុកចូលចាំជិតចាំដាក់ វា បើថាយើងឆ្លេឆ្លាលនឹងអាគ្រាប់វាផ្លោងនឹង ដឹងថាត្រូវហើយ ។

វណ្ណៈ : ចុះបងនៅនេះយូរហើយ បងឃើញប្រជាជនសង្កេតនៅស្រុកភូមិយើងនេះ តើគាត់ប្រកប មុខរបរអ្វី ហើយទៅស៊ីឈ្នួលនៅប្រទេសថៃមានតិចតួច ឬក៏មានច្រើនដែលសព្វថ្ងៃនេះ?

ស៊ុន : បើនិយាយពី១០ ទៅតែ២ទេ ដែលគ្មានឆ្លងទៅមកវិញល្ងាច ។ បើនិយាយខាងគាត់ជីវភាព គាត់វិញ មានតែចំការ ដំឡូងទៅ អីទៅខ្លះគាត់មានច្រើនខ្លះមានតិចទៅ ។ មុខរបរនៅថៃ កាប់ផ្លែឈើចឹងទៅ មកវិញ ខ្លះគាត់ទៅចាំងស្មៅល្ងាចគាត់មកវិញ... ។

វណ្ណៈ : ដោយសារបងដូចថាជាអ្នករស់នៅខាងតំបន់ដូចថា បាត់ដំបង ប៉ៃលិនអីចឹង តើបងពី សង្គមអាចដឹងនេះមានភូមិមានអី ឬក៏ព្រៃស្ងួត?

ស៊ុន : សុទ្ធព្រៃ ប៉ុន្តែកាលនោះ ខ្ញុំមានដូចថាកាលខ្ញុំនៅប៉ៃលិន មានដូចថាកន្លែងគាព្រំរីក នៅ កំរៀង ហើយមានថៃនោះដួលលួចអារឈើអារអីដែរខ្ញុំឃើញពីតូចៗ ទាហានខ្មែរនឹងចាប់ ឡានថៃបានដែរ វាលួចមកអារឈើកាលម៉ាហ៊ុកលន់ នល់ ចាប់កាលនឹងអត់ទាន់មានខាង ខ្មែរក្រហមប៉ុន្មានទេ ខ្មែរក្រហមមានតែភ្នំវៃចាប កាលនោះតិចៗកើតនៅភ្នំវៃចាបនោះ

ទេ ។ ហើយកងខ្មែរក្រហមដើរឃោសនាអី ខ្ញុំចេះស្ដាប់ទៅមានតែកាំបិតកាំភ្លើង កាំបិតស្នៀតកាំបិតអីនឹង ។ ចឹងម្ដុំនេះតាមស្ដាប់នឹងគ្មានភូមិគ្មានអីទេ មានតែខ្ទមដីរនឹងយាមនឹងឯង ថៃវាអាចមកលួចកាប់មែន ។ ប៉ុនឃើញគេចាប់មក ឡានដឹកឈើថៃ ខ្ញុំនៅតូចៗខ្ញុំទៅមើល គេថាឡានសៀម ។

វណ្ណៈ : អានឹងពីសង្គម?

ស៊ុន : បាទ!ពីសង្គម ។

វណ្ណៈ : ពីសង្គមចាស់ ជិនាន់លន់ នល់?

ស៊ុន : បាទ! ជិនាន់ លន់ នល់ មានដែរខាងថៃ ។

វណ្ណៈ : ចុះពួពាក្យថៅកែយ័រៗ អានឹងមានយូរហើយ ឬក៏យ៉ាងម៉េច?

ស៊ុន : អូ! មានយូរហើយ ខ្ញុំមិនទាន់កើតផងមិនដឹង ថៅកែយ័រនឹង ។

វណ្ណៈ : ប្រហែលជាអាចមកជ្រាតកាប់ឈើកាប់អី កាលនឹងគ្មានអ្នកណាមកដល់នឹងបាន ។

ស៊ុន : អត់ទេ ។

វណ្ណៈ : អត់មានអ្នកណាបាន សុទ្ធតែព្រៃសុទ្ធតែអី ។

ស៊ុន : បាទ! មានទាហាននឹងហើយ ទាហានតាព្រំរីកនឹងហើយ ។

វណ្ណៈ : ទាហានតាព្រំរីកនឹង ប្រហែលជាមានតែកំរៀងនឹងតិចទេ?

ស៊ុន : បាទ! នឹងឯងមានម៉ាចំនុចនឹង ។ ហើយម៉ាឡៃតាអ៊ិន តាំ ធ្វើតែស្រែទេ ។ ទាហានគាត់នឹងថាតាអ៊ិន តាំៗនឹង ខ្ញុំនៅតូចខ្ញុំនៅចាំ ខ្ញុំទាហានលន់ នល់ ខ្ញុំនៅប៉ៃលិននេះខ្ញុំដឹង ។

វណ្ណៈ : ចុះខ្ញុំសួរម៉ាសំនួរទាក់ទងនឹងការកាត់ទោសរាល់ថ្ងៃ ពូមានតាមដានខ្លះទេ តុលាការកាត់ទោសនឹង?

ស៊ុន : ពេលបើកទូរទស្សន៍ទៅខ្ញុំមើល ខ្ញុំចូលចិត្តមើលដែរ ចង់ដឹងម៉េចៗខ្ញុំដឹងអាចសន្និដ្ឋានបានខ្លះខ្ញុំមិននិយាយទេ ប៉ុនខ្ញុំអាចសន្និដ្ឋានការកាត់ទោសនេះវាចេះៗ ខ្លះទៅវាក្ដៅក្រហាយទៅខ្លះទៅវា យើថងបានសុខសាន្តត្រាណហើយវាចេះចុះទៅ យើងស្ដាប់ពីក្រៅ ។

វណ្ណៈ : បាទ! អានឹងជាទស្សនៈរបស់គាត់រៀងៗខ្លួន ។

ស៊ុន : បាទ!រៀងខ្លួនទេ យើងនៅយើងមិនវិភាគអានេះចេះៗ ដល់យើងបានចេះមកចុះឯងម៉េចធ្វើចេះ ទៅអានឹងផងវាពិបាកដែរ ខុសគ្នា ។

វណ្ណៈ : ចុះពូគិតថាមានតុលាការកាត់ទោសតែថ្នាក់ដឹកនាំកំពូលប៉ុន្មាននាក់នឹង ពូគិតថាតុលាការនឹងជាការកាត់ទោសចឹងជាការត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវដែរ នេះជាទស្សនៈរបស់ពូទេ អត់មានបញ្ហាអីទេ ។

ស៊ុន : ខ្ញុំពិនិត្យមើលការកាត់ទោសខ្មែរក្រហមនេះ ដែលខ្ញុំបានមើល ហើយពិចារណាក្នុងខ្លួនខ្ញុំជា ការត្រឹមត្រូវមួយសម្រាប់ប្រជាជនមួយចំនួនដែលគាត់ត្រេកអរ គាត់ចង់បានឃើញយុត្តិ ធម៌ ចឹងខ្ញុំមើលក្នុងទូរទស្សន៍ទៅ វាគក្រឹកគក្រោះទៅឃើញតាមនោះឡើងបកស្រាយទៅ ស្តាប់ភាសានឹងទៅខ្លះគាត់មានកំហឹងខ្លះទៀតគាត់មិនមានកំហឹងជារឿងធម្មតា តែជាត្រឹម ត្រូវ ។ គាត់មិនមានកំហឹងប៉ុន្មានតែជាត្រឹមត្រូវ ។ ដូចខ្ញុំក៏ពាក់ព័ន្ធម៉ែឪស្លាប់ដែរ វាមិន ប្រទ្បាតទេ វាគ្រាន់តែមើលទៅវានេះជារឿងវាសនារបស់យើងបណ្តោយទៅ ។

វណ្ណៈ : បាទ! អានេះស្លាប់ទូទៅ?

ស៊ុន : បាទ! ស្លាប់ទូទៅ ។

វណ្ណៈ : ឪពុកគេក៏ស្លាប់ ឪពុកយើងក៏ស្លាប់?

ស៊ុន : បាទ! អានេះទាំងអស់វាជាទូទៅ ។

វណ្ណៈ : ដូចយាយខ្ញុំមកពោធិ៍សាត់នេះ ៣គ្រួសារ អត់មានទៅវិញម្នាក់ទេ ប៉ុន្តែបើតាមដែលមីងធ្លាប់ ដែលនិយាយប្រាប់ថាគាត់ស៊ីកូនបានរស់នឹង គាត់នៅភូមិជាមួយយាយខ្ញុំដែរហើយ គាត់ថា គ្រួសារបងប្អូនខ្ញុំនឹង នៅអាភិរម្យមួយកាលនឹងអាយុប្រហែលជា៤ឆ្នាំពេលជ្រួល ច្របល់ គាត់ឃើញវារត់នៅក្នុងសហករណ៍ដែរ តែគាត់អត់បានចាប់មកគាត់ថាអារម្មណ៍ មិនដឹងហោះហើរទៅណាទេ ពេលនឹង ពេលដែលយួនចូលមក គាត់អរ ។ ហើយម៉ែខ្ញុំក៏ គាត់បន្ទោសដែរ អឺ!បងឯងទាញដៃក្មួយមកផងមិនទាញទេ ។ ហើយខ្ញុំមិនដឹងថារកម៉េច បើក្មេងអាយុ៤ឆ្នាំ នៅក្នុងសម័យ៧៩នោះ ហើយក៏បាត់ឈឹងទាល់ឥឡូវទៅ ។ នឹង គ្រួសារខាងយាយខ្ញុំមក៣គ្រួសារនឹងគាត់នៅលាចណោះ ។ លាចនឹង ថាវេទនាជាងបាត់ ដំបងទៀតតាមមើល ។

ស៊ុន : បាទ! ចឹងបានពាក់ព័ន្ធ និយាយតាមតុគុយទាវ តុអីប្អូនឯងនិយាយមិញបងចាប់អារម្មណ៍ ថា

ខ្ញុំកាលនឹងឃើញវៀតណាមចូលមកនិយាយពីអរអើយអរ ខ្លះទៀតថាពួក៧មករាពួកអី ចេះចង់ដឹង អាផាប់អើយកុំបានអានឹងកុំអីផាប់ហើយ នឹកក្នុងចិត្តខ្លួនឯង ។ យើងកុំគិតអី គិតថាសង្គ្រាម ឥឡូវយើងបានសុខហើយ តើអ្នកណាជួយយើងអ្នកណាផ្តល់ឲ្យយើងៗគិត តែប៉ុននឹង គេឲ្យការ៉េមម៉ាដើមយើងអរគុណគេទៅ យើងកុំភ្លេច ។

វណ្ណៈ : បើយើងគិតមើល មិនមែនថាយើងកាន់ជើង រកពាក្យយុត្តិធម៌ដែរណា ឧបមាថានៅក្នុងសម័យខ្មែរក្រហម បើសិនជាអត់មានវៀតណាមជួយ វៀតណាមពីងពាក់វៀតណាមមកទេ ខ្មែរក្រហមសម្លាប់គ្នាឯងចាប់ផ្តើមតើ ។ ចាប់ផ្តើមសម្លាប់វិលជុំ ចឹងមុនក្រោយគឺគេសម្លាប់ទាំងអស់ ។

ស៊ុន : សម្លាប់ទាំងអស់ម៉ង ។

វណ្ណៈ : មកដល់នេះដូចមីងនិយាយចឹង ឃើញទេ មកដល់សម័យ៧៩ហើយ នៅមានគុកនៅក្នុងព្រៃនឹងទៀត សម្លាប់ខ្មែរក្រហមដែលមិននេះទៀត បាញ់គ្នាទៅវិញទៅមក បាញ់គ្នាសម្លាប់គ្នាទៀត ។ ចឹងបានថាគោលនយោបាយមិនដឹងថាយើង ថាដឹងមកពីណាទេ ចឹងបានថាការកាត់ទោសយើងអត់ដឹងស-ខ្មៅច្បាស់លាស់ទេ ។

ស៊ុន : ប៉ុន្តែសម្រាប់ខ្លួនខ្ញុំមួយនេះ បានដូចថាបើនិយាយទៅបានវៀតណាមបណ្តោយ កុំអីខ្ញុំអត់បានមកចេះទេ ។ ឃើញពេលដែលខ្ញុំរត់ឃើញវៀតណាមកឆីបៗ ពេលកំពុងរត់ទ័ពគេបែង បែកទៅណាទៅណោបាត់ យើងរួចខ្លួន ។

វណ្ណៈ : យើងលែងមានសង្គ្រាម បានប្រទេសយើងទៅមុខទៀត ហើយយើងច្បាំងខ្មែរនិងខ្មែរគ្នាឯង ។ ដូចបងធ្វើទាហានលន់ នល់ចឹង ដូចមានឯកសារនៅកន្លែងខ្ញុំអី ខ្ញុំមើលឯកសារអាណិតណាស់ បោះទាំងឡានៗគរទាំងឡានដូចគល់អុសចឹង ហើយសួរថាផាប់ពីណាគេខ្មែរ ។ ដោយសារអ្នកនយោបាយមួយចំនួន ដូចថាមិនបានគិតពីផលប៉ះពាល់ តែឥឡូវយើងគិតច្បាស់ហើយ បងប្អូនខាងកំរៀងដែលខ្មែរក្រហម បើវ៉ៃខ្មែរនិងខ្មែរ សួរគាត់ៗថាមិនទៅទេ បើវ៉ៃជាមួយបរទេសទៅទៀត ។ តែបើគាត់មិនទៅមានន័យថាទឹកចិត្តគាត់បានប៉ុននេះដែរ ។

ស៊ុន : និយាយទៅមិននេះទេ បើនិយាយពីសម័យណា បើអ៊ំគាត់និងខ្ញុំមិនខុសគ្នាទេ ខ្ញុំឃើញសម័យនេះ អ្នកដឹកនាំសម័យនេះខ្ញុំអរ ព្រោះវាដូចខុសពីមុននិយាយចឹងម៉ងទៅ ។ ថាសឹងពេលឃើញទូរទស្សន៍ចង់ស្រក់ទឹកភ្នែកជួសគាត់ ឃើញចុះអោបប្រជាជន ឃើញចេះ ឯង

រកទៅ បើលន់ នល់ មិនដែល ស្អែកហ៊ានទៅព្រំដែន គ្រោះថ្នាក់ប៉ុននឹងគាត់ហ៊ានទៅ ។ បានន័យថាខ្ញុំសរសើរ ហើយខ្ញុំស្រឡាញ់សម្ដេច ។

វណ្ណៈ : សម័យសមាហរណកម្ម គាត់ហ៊ានចុះយន្តហោះនៅម៉ាឡៃអី ។

ស៊ុន : បាទ! យើងមើលថ្នាក់ដឹកនាំ ។

វណ្ណៈ : បាទ! ចុះ៣៧នឹង ។

ស៊ុន : អានេះហើយ បានដូចខ្ញុំនិយាយថាឡើងសក្តិពីតូចដល់នឹង ។ ហើយគាត់ពីដើមគាត់ធ្វើអីគាត់និរសាគេដែរ ដល់គាត់ដល់ធំចឹង ។ នេះឯងដែលខ្ញុំនិយាយឲ្យប្អូនឯងស្តាប់មិញនេះណាឡើងពីហ្វេហ្វាម មកបេះដឹងណាស់ ដឹងទុក្ខធុរៈអ្នកអត់ណាស់បានដឹង ។

អ្នកជិតខាង : គាត់និរសាតាប៉ុល ពត ។ ដល់ហើយគាត់រៀនតាំងពីនឹងហើយ ដាប់អ៊ំៗនឹង គាត់យល់ណាស់ គាត់មានបទពិសោធន៍តាម គាត់និរសា ។

វណ្ណៈ : ហើយឥឡូវដូចសមាហរណកម្ម ឧបមាថាគាត់និយាយជាមួយមេៗត្រូវហើយ ឧបមាថាចឹង ប៉ុន្តែចុះមកទឹកដីខ្មែរក្រហមសុទ្ធសាធ បើគេប្រែប្រួល គេបាញ់មិនអាចឡើងយន្តហោះបានទេ ។

អ្នកជិតខាង : គ្មានអ្នកណាបាញ់ គេបន់ឲ្យចប់គ្រប់តែគ្នា ទាំងគេទាំងខ្ញុំ អរចង់ងាប់ហើយ ។

វណ្ណៈ : ប៉ុន្តែយើងគិតចឹង ប៉ុន្តែអានេះគាត់ប្រថុយមកដែរមិនដឹង?

ស៊ុន : បាទ!

វណ្ណៈ : បើសិនជាមានអ្នកញ៉ុះញ៉ង់ ត្រូវសម្លាប់ក៏សម្លាប់បានដែលពេលចុះមក ប្រថុយដែរនឹង ។

អ្នកជិតខាង : គាត់មក គ្រាន់ផ្តាច់ខ្លួនហើយមកដល់ភ្លាម ប៉ុនពួកខ្មែរក្រហមនេះលោកអើយបន់ឲ្យចប់ សឹងអង្គរសែងម្នាក់ៗ ។

ស៊ុន : ចុះទាហានខាងក្នុងបន់ឲ្យចប់ដែរនឹង ខ្ញុំនេះមកជាប់នឹងអំពិល៥ដើមនេះៗ ដេកចាំ ដល់ពេលស្អែកខាងស្អែកឃើញខ្មែរក្រហមទៅទិញអីវ៉ាន់នៅបវេល អរងាប់ ។ បានប៉ុននេះយើងអរហើយ យើងមិនចង់ទៀតទេ ។

វណ្ណៈ : ចឹងការសម្ភាសន៍ខ្ញុំជាមួយពូ គឺខ្ញុំអរគុណពូច្រើនដែលបានចូលរួមនិយាយពីរឿងទុក្ខសោកនៅក្នុងសម័យខ្មែរក្រហមដែលពូបានឆ្លងកាត់ណ៎ពូណា ។

ស៊ុន : បាទៗ ។

វណ្ណៈ : ហើយខ្ញុំអរគុណពូច្រើន ។

«ចប់»